# ឧបសម្ព័ន្ធ ១

## I. សាវតារ

១. នៅក្នុងខែ សីហា ឆ្នាំ ១៩៧៩ លោក អៀង សារី ត្រូវបានជំនុំជម្រះ និងកាត់ទោសកំបាំងមុខ ចំពោះការប្រព្រឹត្តបទប្រល័យពូជសាសន៍ ក៏ដូចជា បទឧក្រិដ្ឋដទៃផ្សេងទៀត[1]។ សាលាក្រមនៃការជំនុំជម្រះឆ្នាំ ១៩៧៩ បានសម្រេចកាត់ទោសប្រហារជីវិត លោក អៀង សារី និងរឹបអូសទ្រព្យសម្បត្តិរបស់គាត់ទាំងអស់[2]។ លោក អៀង សារី មិនត្រូវបានឃុំខ្លួនមុន ក្នុងអំឡុងពេល ឬក្រោយពេលជំនុំជម្រះក្តីឡើយ ហើយដូច្នេះ ទោសដែលបានសម្រេចនោះ មិនត្រូវបានអនុវត្តនោះទេ។

---

[1] លោក អៀង សារី ត្រូវបានជំនុំជម្រះក្តី និងផ្តន្ទាទោស *កំបាំងមុខ* ថាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ បន្ថែមពីលើបទល្មើសដូចជា៖

I. អនុវត្តន៍នូវផែនការសម្លាប់រង្គាលដោយមានខ្សែរយៈប្រព្រឹត្តទៅលើប្រជាជនគ្រប់ស្រទាប់ គ្រប់ប្រភេទ ក្នុងសភាពសាហាវឃោឃៅបំផុត សម្លាប់រង្គាលគ្មានរើសមុខ ថានេះជានាយទាហាន ឬជាពលទាហាននៃរបបចាស់ សម្លាប់រង្គាលនូវបញ្ញាវន្តគ្រប់ជាន់ថ្នាក់ សម្លាប់រង្គាលទាំងមនុស្ស ទាំងចលនាដែលពួកវាយល់ថាប្រឆាំងនឹងពួកវា។

II. ការកាប់សម្លាប់អ្នកដឹកនាំសាសនា សាសនិកជន ការលប់បំបាត់សាសនា កាប់សម្លាប់ជនជាតិភាគតិច ដោយគ្មានរើសមុខរវាងអ្នកប្រឆាំង ឬអ្នកមិនប្រឆាំង ដោយក្នុងគោលបំណងធ្វើសមានកម្ម កម្ទេចជនបរទេស។

III. ការបណ្តេញប្រជាជនឲ្យចេញពីរដ្ឋធានីភ្នំពេញ ពីទីក្រុង និងជនបទ ដែលទើបរំដោះ នាំឲ្យមានការវិនាសហិនហោចដល់មូលដ្ឋានគ្រួសារ មូលដ្ឋានសង្គម និងនាំឲ្យមានការសម្លាប់រង្គាលដល់ពូជមនុស្ស។

IV. ប្រមូលបង្ខំប្រជាជនឲ្យចូល "សហករណ៍" ដែលជាជំរំប្រមូលផ្តុំក្លែងភេទ កៀបសង្កត់ប្រជាជនឲ្យធ្វើការ នឹងឲ្យរស់នៅក្នុងលក្ខណៈវិនាសអន្តរាយ ទាំងរូបកាយ ទាំងស្មារតី សម្លាប់ ព្យាបាទយ៉ាងរង្គាល។

V. ឃាតកម្មលើរូបកុមារ និងការបង្វឹកកុមារជំទង់ឲ្យទៅជាជនសាហាវឃោរឃៅកាចសាហាវក្រៃលែង។

VI. បំផ្លាញសម្ព័ន្ធសេដ្ឋកិច្ច បំផ្លាញឃឿនវប្បធម៌ អប់រំ ឃឿនសុខាភិបាល។

VII. ក្រោយត្រូវកងកម្លាំងប្រដាប់អាវុធបរិសុទ្ធ វាយរំលំបន ប៉ុល ពត, អៀង សារី នៅតែរឹងរូសបន្តការប្រឆាំងនឹងបដិវត្តន៍ ដោយប្រព្រឹត្តបទឧក្រិដ្ឋថ្មីៗទៀត ក្នុងការសម្លាប់រង្គាលជនទាំងឡាយ ដែលបដិសេធមិនធ្វើតាមពួកគេ។ ក្នុងរយៈពេល៤ឆ្នាំដឹកនាំប្រទេស បន ប៉ុល ពត អៀង សារី បានអនុវត្តមាគ៌ាធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។

*សូមមើល* សាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍ ឆ្នាំ ១៩៧៩ ទំព័រ៣-២១។

[2] *ឯកសារដូចខាងលើ* ទំព័រ ៣៩។

២. នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤ រដ្ឋសភាជាតិកម្ពុជាបានប្រកាសឱ្យប្រើប្រាស់នូវ "ច្បាប់ស្តីពីការដាក់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ឱ្យនៅក្រៅច្បាប់" ("ច្បាប់ឆ្នាំ ១៩៩៤")[3]។ ច្បាប់ឆ្នាំ ១៩៩៤ ប្រកាស (ក្នុងចំណោមចំណុចផ្សេងៗទៀត)ថា ក្រុម "កម្ពុជាប្រជាធិបតេយ្យ" និងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន ត្រូវបានដាក់ឱ្យនៅក្រៅច្បាប់ ហើយថាសមាជិកនៃក្រុមនេះ មិនស្របទៅនឹងច្បាប់នោះទេ[4]។ ច្បាប់ឆ្នាំ ១៩៩៤ ត្រូវបានតាក់តែងឡើង ក្នុងគោលបំណងបង្ហាញពីកិច្ចខិតខំព្យាយាមដ៏ច្បាស់លាស់មួយ ដើម្បីបញ្ចប់សង្គ្រាម[5] និងដើម្បីច្បាប់ផ្តើមដំណើរការផ្សះផ្សាជាតិ ។

៣. នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦ លោក អៀង សារី បានចេញសេចក្តីប្រកាសមួយ ដោយថ្កោលទោស ប៉ុល ពត, តាម៉ុក និង សុន សេន ហើយបានប្រកាសថា គាត់ និងកូនចៅរបស់គាត់ "នឹងចុះចូលរួបរួមជាតិទាំងមូល ដើម្បីឱ្យមានការផ្សះផ្សាជាតិដោយបរិសុទ្ធ ដែលនេះវាផ្ទុយទាំងស្រុងទៅនឹងការគិតដ៏គ្មានហេតុផលរបស់ពួកស្រេកឈាម ប៉ុល ពត, តាម៉ុក និង សុន សេន ដែលនឹងបន្តធ្វើសង្គ្រាមរហូតដល់ថ្ងៃស្លាប់"[6]។

៤. នៅដើមខែ កញ្ញា ឆ្នាំ ១៩៩៦ លោក អៀង សារី បានជួបជាមួយ ទៀ បាញ់ និង ទា ចំរ៉ាត់ ដែលជាសហរដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា នៅទីក្រុងបាងកក ដើម្បីស្នើសុំការលើកលែងទោស ជាថ្នូរនឹងការចុះចូលរបស់ក្រុមគាត់ជាមួយនឹងរដ្ឋាភិបាល។ ឧត្តមសេនីយ៍ ទៀ បាញ់ "កោតសរសើរ អៀង សារី ចំពោះទឹកចិត្តស្មោះសររបស់គាត់ចំពោះការបង្រួបបង្រួមជាតិ ដោយបានលើកឡើងថា

---

[3] ច្បាប់ស្តីពីការដាក់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ឱ្យនៅក្រៅច្បាប់ ប្រកាស ដោយ ព្រះរាជក្រម លេខ១ នស ៩៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤។

[4] *ដូចឯកសារខាងលើ*។ មាត្រា១-២។ ច្បាប់នេះអនុគ្រោះទុលពេល៦ខែ ក្រោយពីចូលជាធរមានឱ្យជនជាសមាជិកអង្គការនយោបាយ ឬជាកម្លាំងយោធានៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" វិលត្រឡប់មករួមរស់ ក្រោយការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ *សូមមើល* ច្បាប់ឆ្នាំ ១៩៩៤ មាត្រា៥។

[5] "រដ្ឋសភាជាតិបានអនុម័តច្បាប់ស្តីពីការដាក់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ឱ្យនៅក្រៅច្បាប់ ដោយចេតនាចង់បញ្ចប់សង្គ្រាម..." គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្ស ការពិចារណាលើរបាយការណ៍ ដែលដាក់ដោយភាគីរដ្ឋ ដោយអនុលោមតាមមាត្រា៤០ នៃកតិកាសញ្ញានេះ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៨។ ឯកសារលេខ CCPR/C/81/Add.12 កថាខណ្ឌ១០៥។

[6] *អៀង សារី សេចក្តីប្រកាសរបស់ អៀង សារី ឆ្នាំ ១៩៩៦* **ទស្សនាវដ្តីស្វែងរកការពិត មជ្ឈមណ្ឌលឯកសារកម្ពុជា** ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦។

ការសម្រេចចិត្តរបស់គាត់ក្នុងការបញ្ចប់សង្គ្រាមប្រដាប់អាវុធ ដែលមានរាប់ទសវត្សរ៍មកហើយ ពិតជានឹងនាំឲ្យមានការរួបរួមជាតិ នៅទូទាំងប្រទេស"[7]។ ឧត្តមសេនីយ៍ ទៀ បាញ់ បានលើកឡើងថា "ការសម្រេចរបស់លោក អៀង សារី មានតម្លៃធំធេងមិនអាចវាស់វែងបានទេ ដោយហេតុថា វានឹងបញ្ចប់សង្គ្រាម សន្សំសំចៃថវិកា និងជៀសវាងនូវការបាត់បង់ជីវិត" និងបានសង្កត់ធ្ងន់ទៀតថា វាគ្រាន់តែជាបញ្ហាពេលវេលាប៉ុណ្ណោះ ដែលថា លោក អៀង សារី និងកូនចៅរបស់គាត់នឹងទទួលបានការលើកលែងទោសនោះ[8]។

៥. នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៩៩៦ លោក អៀង សារី បានប្រគល់ឯកសារមួយទៅឲ្យរដ្ឋាភិបាល ដែលមានចំណងជើងថា "ការពិតអំពីអំពើផ្តាច់ការក្នុងរបប ប៉ុល ពត" ដែលបង្ហាញអំពី **ក**) តួនាទីរបស់បក្ស និងរដ្ឋាភិបាល **ខ**) អ្នកគ្រប់គ្រងអំណាច **គ**) ប្រព័ន្ធសេដ្ឋកិច្ច **ឃ**) ប្រព័ន្ធអប់រំ **ង**) គោលនយោបាយបរទេស និង **ច**) ប្រព័ន្ធផ្សេងៗទៀត នៅក្នុងរបប ប៉ុល ពត[9]។

៦. នៅក្នុងការចរចា ដើម្បីចុះចូលជាបន្តមកទៀត សហនាយករដ្ឋមន្ត្រី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងព្រះអង្គម្ចាស់ទ្រង់ នរោត្តម រណឫទ្ធិ បានចូលគាល់ព្រះមហាក្សត្រ សម្តេច នរោត្តម សីហនុ ដោយស្នើសុំព្រះរាជប្រទានលើកលែងទោស និងអនុគ្រោះទោសឲ្យ លោក អៀង សារី។ ព្រះមហាក្សត្របានយល់ព្រមផ្តល់ព្រះរាជប្រទានលើកលែងទោស និងការអនុគ្រោះទោស ដ៏រាបណាមានការគាំទ្រពីសមាជិកសភាជាតិចំនួន២/៣ ចំពោះព្រះរាជប្រទានលើកលែងទោស និងការអនុគ្រោះទោសនេះ[10]។ សមាជិកសភាក៏បានគាំទ្រសំណើសុំព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ដែលនាយករដ្ឋមន្ត្រីបានស្នើ[11]។

---

[7] *សូមមើល អៀង សារី ចរចាការលើកលែងទោស៖ អ្នកចរចាយោធាជជែកសម្ងាត់ជាមួយរដ្ឋមន្ត្រី* BANGKOK POST ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៦។

[8] *ដូចឯកសារខាងលើ*។

[9] ហេតុពិតអំពីរបបផ្តាច់ការរបស់ ប៉ុល ពត ឆ្នាំ ១៩៧៥-១៩៧៨ ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៩៩៦ ERN: 00081213-00081222។

[10] ព្រះមហាក្សត្រមានព្រះរាជបន្ទូលនៅពេលនោះថា "ក្នុងព្រះនាមជាព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ ដែលគ្រងរាជ ប៉ុន្តែមិនកាន់អំណាច ខ្ញុំព្រះករុណាត្រូវបំពេញចិត្តដល់សហនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងបញ្ហាផ្តល់ការលើកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្រកម្ម អនុលោមតាមវិធាន៨៩ (គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោស) របស់ អៀង សារី

៧. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ព្រះមហាក្សត្របានអនុវត្តអំណាចស្របច្បាប់របស់ទ្រង់ ដែលផ្តល់ឱ្យដោយរដ្ឋធម្មនុញ្ញ ហើយផ្តល់ឱ្យលោក អៀង សារី នូវព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស។ ព្រះមហាក្សត្របានព្រះរាជទានការលើកលែងទោស និងការអនុគ្រោះទោស "ដោយយកមកពិចារណា" នូវសេចក្តីប្រកាសនាថ្ងៃទី ១៥ ខែ សីហា របស់ លោក អៀង សារី និងឯកសារ ដែលគាត់បានផ្តល់ឱ្យរដ្ឋាភិបាលក្នុងខែ កញ្ញា[12]។ ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ចែងថា៖

> មាត្រា១៖ ត្រូវលើកលែងទោសឱ្យ លោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទី២ ទទួលបន្ទុកកិច្ចការបរទេសក្នុងរដ្ឋាភិបាល នៃប្រទេសកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានផ្តន្ទាទោស ប្រហារជីវិតបង់ និងរឹបអូសទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជាតិបដិវត្តន៍ក្រុងភ្នំពេញ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និង ចំពោះទោសដែលបានកំណត់ដោយច្បាប់ ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ដែលប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម លេខ០១ ចុះថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ ១៩៩៤។

---

លែងទោសនេះឱ្យទៅលោក អៀង សារី និង"អតីត" អ្នកគាំទ្រខ្មែរក្រហម របស់គាត់ដទៃទៀត។ ប៉ុន្តែ ខ្ញុំព្រះករុណានឹងតម្រូវឱ្យមានការគាំទ្រចំនួន២/៣ពីសមាជិកសភាជាតិចំពោះ "បញ្ហា អៀង សារី" ដែលជាបញ្ហាពិសេសមួយនេះ ដើម្បីគាំទ្រដល់សហនាយករដ្ឋមន្ត្រីរបស់យើង មុននឹងព្រះរាជប្រទានទោស ត្រូវផ្តល់ឱ្យ អៀង សារី ជាផ្លូវការ"។ ហ្វាក់ពីសម្តេចព្រះបាទ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ផ្ញើទៅលោក Pierre Sané អគ្គលេខាធិការអង្គការលើកលែងទោសអន្តរជាតិ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៦។

[11] សេចក្តីបំភ្លឺពី សម្តេចព្រះបាទ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៦។ *សូមមើលផងដែរ ព្រះបាទសីហនុ លើកលែងទោសឱ្យ អៀង សារី* BANGKOK POST ចុះផ្សាយថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៦៖ "ព្រះមហាក្សត្របានឡាយព្រះហស្តលេខាលើកលែងទោស... ដោយមានការគាំទ្រពីរភាគបីនៃ(សមាជិក)សភា។ លោកនាយករដ្ឋមន្ត្រីទីពីរ ហ៊ុន សែន បានប្រាប់សារព័ត៌មាន រ៉យទ័រ ថា ហ៊ុន សែន បាននិយាយថា វាជាការងាយស្រួលក្នុងការប្រមូលហត្ថលេខាពីសមាជិកសភាទាំង១២០រូប..."។

[12] ថ្វីត្បិតព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស រាយនាមជាឯកសារចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៩៦ ជាជាង ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៩៩៦ ដែលជាថ្ងៃពិតប្រាកដសរសេរនៅលើឯកសារនោះ។

មាត្រា២៖ ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ។

មាត្រា៣៖ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសម្រេចជាស្ថាពរ[13]។

៨. ជាការតបស្នងចំពោះព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះ លោក អៀង សារី បានចុះចូលខាងរដ្ឋាភិបាលកម្ពុជា ដែលបាននាំឱ្យបញ្ចប់នូវជម្លោះរវាងកងកម្លាំងរបស់រដ្ឋាភិបាល និងកងកម្លាំងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានពន្យល់ថា "បើគ្មានលោក អៀង សារី នាំកងកម្លាំងចំនួន៧០ភាគរយ នៃកងកម្លាំង[ខ្មែរក្រហម] ឱ្យធ្វើសមាហរណកម្មជាមួយនឹងកងកម្លាំងរបស់រដ្ឋាភិបាលនោះទេ យើងក៏មិនអាចបញ្ចប់សង្គ្រាមបានដែរ"[14]។ ទើបតែដល់ពេលនោះតែប៉ុណ្ណោះ ទើបសហគមន៍អន្តរជាតិ និងជាពិសេសអង្គការសហប្រជាជាតិអាចធ្វើឱ្យខ្មែរក្រហមទម្លាក់អាវុធរបស់ខ្លួន ហើយធ្វើសមាហរណកម្មជាមួយនឹងសង្គមកម្ពុជាវិញ[15]។ ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះ ជួយឱ្យទទួលបាននូវ

---

[13] ការបកប្រែនេះត្រូវបានបកប្រែដោយក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់កិច្ចសហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេស និងការរៀបចំដំណើរការនីតិវិធីសម្រាប់ការជំនុំជម្រះមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ដែលបានធ្វើការជាមួយសហគមន៍អន្តរជាតិលើការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតុបករណ៍នានា ដែលនឹងត្រូវប្រើប្រាស់នៅអ.វ.ត.ក។ *សូមមើល* http://www.eccc.gov.kh/en/chronlologies/royal-government-created-its-task-force-cooperation-foreign-legal-experts-and-preparat។ ការបកប្រែនេះមានមើលបានក្នុងបញ្ជីឯកសារច្បាប់របស់អវតក នៅលើ "G Drive" ដែលភាគី និងអង្គជំនុំជម្រះទាំងអស់នៃអ.វ.ត.ក អាចចូលមើលបាន។ ការបកប្រែនេះក៏ជាការបកប្រែដំបូងគេបង្អស់ ដែលគេបានដាក់នៅក្នុងសំណុំរឿង។ *សូមមើល* ឯកសារ D366/7.1.191។

[14] *ច្បាប់ស្តីពីតុលាការខ្មែរក្រហម កំពុងរង់ចាំការអនុម័តនៅខែធ្នូ ៖ នាយករដ្ឋមន្ត្រីកម្ពុជា* សារព័ត៌មានបារាំងឈ្មោះ AGENCE FRANCE-PRESSE ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០។

[15] ជាឧទាហរណ៍ កិច្ចនេះត្រូវបានព្យាយាមធ្វើឡើងតាមរយៈកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលផ្តល់លទ្ធភាពឱ្យពួកខ្មែរក្រហមអាចចូលរួមក្នុងការបោះឆ្នោតជាសកលបាន។ *សូមមើល* កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ឧសម្ព័ន្ធ៣(៣)។

លទ្ធផលនេះ[16]។ នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៦ គ្រាន់តែរយៈពេលមួយខែក្រោយពីមានព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស សារព័ត៌មាន Asiaweek បានរាយការណ៍ថា៖

> ហ៊ុន សែន បានប្រាប់ Asiaweek ថា ការចាកចេញរបស់ អៀង សារី នឹងបង្កឱ្យមានការចុះចូលដ៏ទូលំទូលាយ ហើយធ្វើឱ្យចំនួនពួកខ្មែរក្រហមធ្លាក់ចុះរហូតដល់៨០%ឯណោះ។ ប៉ុន្តែ ការបែកបាក់នោះហាក់ដូចជា កើតឡើងលឿនជាងការប៉ាន់ស្មានដ៏សុទិដ្ឋិនិយមរបស់ ហ៊ុន សែន ទៅទៀត។ កាលពីមួយសប្តាហ៍មុន កងពលចំនួនប្រាំបី ដែលរួមមានយុទ្ធជនស្មើរតែ២.៥០០នាក់ តាមការគណនាត្រួសៗ បានចុះចូលជាមួយរដ្ឋាភិបាល[17]។

៩. ដោយសារតែលទ្ធផលទាំងនេះហើយ បានជាការសម្រេចរបស់ព្រះមហាក្សត្រ ដែលសម្រេចផ្តល់ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ត្រូវបានគាំទ្រដោយសាធារណជនកម្ពុជាភាគច្រើន៖

> សាធារណជនមិនត្រឹមតែយល់ស្របតែប៉ុណ្ណោះទេ ពួកគេថែមទាំងគាំទ្រដល់ការលើកលែងទោសរបស់រដ្ឋាភិបាលផងដែរ។ ការស្ទង់មតិមួយដែលបានធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ...(SODECO) បានបោះពុម្ពផ្សាយការរកឃើញរបស់ខ្លួន នៅក្នុងសារព័ត៌មាន ឌឹ ឃែមបូឌា ដេលី នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៧ ដោយមានរាយការណ៍ថា ពីរភាគបីនៃអ្នកត្រូវបានស្ទង់មតិទាំងអស់ចំនួន១.១២០ នាក់នោះ "ពេញចិត្ត" ចំពោះការចរចាដោះដូរជាមួយនឹង អៀង សារី និងការស្ទង់មតិតាមផ្លូវរបស់កាសែត ភ្នំពេញប៉ុស្តិ៍មួយដែលបានបោះពុម្ពផ្សាយនៅក្នុងសារព័ត៌មានសម្រាប់ថ្ងៃទី ២៣ ខែ សីហា ដល់ ថ្ងៃទី ៥

---

[16] "ការចុះចូលរបស់ លោក អៀង សារី បានជួយបង្កឱ្យមានការសម្របសម្រួលនយោបាយគ្រប់ទីកន្លែង។ រណឫទ្ធិ និង ហ៊ុន សែន មើលឃើញឱកាសបំបែកពួកខ្មែរក្រហមទាំងមូល ហើយបានចាប់ផ្តើមធ្វើការចរចាដោយឡែកពីគ្នា ជាមួយនឹងមេដឹកនាំមួយចំនួនដែលនៅជុំវិញ ប៉ុល ពត រួមទាំង សុន សេន ផងដែរ ដែលជាមុខសញ្ញារបស់ ប៉ុល ពត នៅក្នុងឆ្នាំ ១៩៧៨ មុនពេលការឈ្លានពានរបស់វៀតណាម"។ ELIZABETH BECKER, នៅពេលដែលសង្គ្រាមរលត់ទៅ៖ ប្រទេសកម្ពុជា និងពួកបដិវត្តន៍ខ្មែរក្រហម លេខ៥១៥ (បោះពុម្ពដោយកិច្ចការសាធារណៈ ឆ្នាំ ១៩៩៨)។ *សូមមើលផងដែរ* ឯកសាររបស់ PHILIP SHORT *ប៉ុល ពត* ៖ ការវិភាគលើសុបិន្តអាក្រក់មួយ លេខ ៤៣៧ (បោះពុម្ពដោយ Henry Holt និង Company ឆ្នាំ ២០០៤)។ "ការចុះចូលរបស់ អៀង សារី គឺជាការបាត់បង់មួយ ដែលពួកខ្មែរក្រហមនឹងមិនអាចទទួលបានមកវិញទេ"។

[17] អត្ថបទ Dominick Faulder *បង្ហូរឈាមខ្មែរក្រហម* សារព័ត៌មាន ASIA WEEK ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៦។

បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្រកម្ម អនុលោមតាមវិធាន៨៩ (គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោស) របស់ អៀង សារី

ខែ កញ្ញា ឆ្នាំ ១៩៩៦ ក៏បានបង្ហាញពីការរកឃើញស្រដៀងគ្នានេះដែរ។ (អង្គការ សមាគម សាមគ្គីភាព និងការអភិវឌ្ឍសហគមន៍ (SODECO) នេះមានភាពស្និតស្នាលជាមួយនឹង មេដឹកនាំគណបក្ស សម រង្ស៊ី)[18]។

១០. នៅក្នុងខែ សីហា ឆ្នាំ ១៩៩៨ ក្រោយពីការចាប់ខ្លួន នួន ប៉ែត ដែលជាអតីតសមាជិកខ្មែរក្រហម មួយរូប លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ លោក ទៀ បាញ់ ដើម្បីធានាដល់ លោក អៀង សារី ថាអភ័យឯកសិទ្ធិដែលបានផ្តល់ទៅឲ្យគាត់នោះមិនត្រូវរង ការគំរាមកំហែងទេ[19]។

១១. នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ លោក អៀង សារី ត្រូវបានបញ្ជូនមកឃុំខ្លួននៅមន្ទីរឃុំឃាំង នៃអ.វ.ត.ក[20]។

១២. នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កសចស បានចេញនូវដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលោក អៀង សារី[21]។ ក្នុងដីកាសម្រេចនេះ ក.ស.ច.ស លើកឡើង*តាមគំនិតរបស់ខ្លួនផ្ទាល់ (propio motu)* អំពីបញ្ហាយុត្តាធិការនៃគោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* (*ne bis in idem)* និងអានុភាពនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ដោយពុំបាន

[18] ឯកសាររបស់ លោក នៅ កាស៊ី និង Jeffrey C. Gallup *ផ្សាយក្នុងអត្ថបទ សិទ្ធិមនុស្ស និងអតីតកាលរបស់កម្ពុជា ៖ ការតវ៉ា យកសន្តិភាពមុនយុត្តិធម៌* ផ្សាយក្នុង HUM. RTS. DIALOGUE 1.8 (ឆ្នាំ ១៩៩៧)។ *សូមមើលផងដែរ* ឯកសាររបស់ Louise Mallinder *តើការលើកលែងទោស និងយុត្តិធម៌អន្តរជាតិអាចត្រូវបានផ្សះផ្សាគ្នាបានដែរឬទេ?* លេខ១ ផ្សាយក្នុង INT'L J. TRANSITIONAL JUST. ២០៨ (ឆ្នាំ២០០៧)។ អត្ថបទរបស់ នៅ វណ្ណារិន និង Julia Wallace *ការគាំទ្រ លោក អៀង សារី កើនឡើងនៅម៉ាឡៃ ខណៈពេលដែលការជំនុំជម្រះក្តីខិតជិតមកដល់* ផ្សាយក្នុងសារព័ត៌មាន *ឌឹ ភែមបូឌា ដេលី* ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០។

[19] ឯកសាររបស់ John A. Hall ក្នុងស្រមោលរបស់តុលាការខ្មែរក្រហម៖ ការជំនុំជម្រះដោយតុលាការជាតិលើ នួន ប៉ែត, ឈូក រិន និង សម ប៊ិត និង ការស្វែងរកភាពស្របច្បាប់តុលាការនៅក្នុងកម្ពុជា 5 LAW & PRAC. INT'L CTS. & TRIBUNALS 425 (ឆ្នាំ ២០០៦)។

[20] របាយការណ៍នៃការឃាត់ខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារលេខ C14/I។

[21] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារលេខ C22។

ផ្តល់ជាដំបូងឲ្យភាគីមានឱកាសបញ្ចេញមតិយោបល់អ្វីឡើយលើបញ្ហានេះ។ ដីកាសម្រេចនេះបានកំណត់ថា ទាំងព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស និងគោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* ពុំអាចរារាំងការឃុំខ្លួនរបស់លោក អៀង សារី បានឡើយ។ ដីកាសម្រេចនេះបានកំណត់ថា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនឹងមិនអាចរារាំងដល់ការចោទប្រកាន់ ដោយផ្អែកទៅលើដោយផ្អែកទៅលើអង្គហេតុដែលថា វាយោងទៅលើច្បាប់ឆ្នាំ ១៩៩៤ និងថា ច្បាប់ឆ្នាំ ១៩៩៤ ពុំមានចែងអំពីបទល្មើសនានា ស្ថិតក្រោមយុត្តាធិការ អ.វ.ត.ក ឡើយ។ ដីកាសម្រេចនេះពឹងផ្អែកការកំណត់របស់ខ្លួនថា គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* ពុំរារាំងដល់ការចោទប្រកាន់ ដោយអង្គហេតុថា លោក អៀង សារី កាលនោះ មិនត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ឡើយ ហើយថែមទាំងបានកត់សម្គាល់ទៀតថា ការផ្តន្ទាទោសត្រួតគ្នាត្រូវបានអនុញ្ញាត ក្រោមច្បាប់អន្តរជាតិ ហើយការជំនុំជម្រះ ឆ្នាំ ១៩៧៩ ពុំបានគ្របដណ្តប់រាល់បទល្មើសនានា ដែលស្ថិតក្រោមយុត្តាធិការអ.វ.ត.ក ឡើយ។

១៣. មេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ហើយនៅថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០៨ ស្របទៅតាមការណែនាំរបស់អង្គបុរេជំនុំជម្រះ មេធាវីការពារបានដាក់សារណាស្តីពីបញ្ហា គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* និងការអនុគ្រោះទោស[22]។ មេធាវីការពារក្តីសូមគូសបញ្ជាក់ថា ការចោទប្រកាន់បច្ចុប្បន្នចំពោះលោក អៀង សារី ត្រូវបានរារាំងដោយព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស និង គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ*។ មេធាវីការពារក្តីបានដាក់ឧបសម្ព័ន្ធចំនួនបីភ្ជាប់ជាមួយនឹងទឡ្ហីករណ៍របស់ខ្លួន។ ទឡ្ហីករណ៍ **ក** ប្រៀបធៀបអ.វ.ត.ក ទៅនឹងតុលាការជាតិ និងតុលាការកូនកាត់អន្តរជាតិ។ ទឡ្ហីករណ៍ **ខ** ប្រៀបធៀបធាតុផ្សំអំពីប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ជាមួយនឹងបទល្មើស

[22] សារណារបស់លោក អៀង សារី អនុលោមតាម *សេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី សុំការពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ* ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០៨ ឯកសារលេខ C22/I/26។

បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្រកម្ម អនុលោមតាមវិធាន៨៩ (គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោស) របស់ អៀង សារី

តាមក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ឧបសម្ព័ន្ធ គ ប្រៀបធៀបសាលដីកា អៀង សារី ឆ្នាំ១៩៧៩ ទៅនឹងសេចក្តីសន្និដ្ឋានឲ្យបញ្ជូនរឿងទៅស៊ើបសួរ។

១៤. នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានចេញនូវសាលដីកាមួយ ដែលក្នុងនោះខ្លួនបានកត់សម្គាល់ ពាក់ព័ន្ធនឹងគោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* ថា "បទចោទដែលបានកំណត់ដោយសហចៅក្រមស៊ើបអង្កេត ទោះបីគ្រប់គ្រាន់ក្នុងការប្រាប់ដល់ជនត្រូវចោទអំពីបទចោទ ដែលដាក់បន្ទុកលើខ្លួនក៏ដោយ ក៏បទចោទទាំងនេះ[មានលក្ខណៈ] ស្រពិចស្រពិលមិនអាចឲ្យពិចារណាត្រឹមត្រូវថាតើ ការចោទប្រកាន់នាពេលនោះ គឺផ្អែកលើ "អំពើ" ដដែល ដូចនឹង "អំពើ" ទាំងឡាយ ដែលបានយកមកធ្វើជាសំអាងនៃបទចោទនៅក្នុងឆ្នាំ ១៩៧៩ ឬយ៉ាងណា"[23]។ អង្គបុរេជំនុំជម្រះក៏បានយល់ឃើញនៅគ្រានោះថា លោក អៀង សារី មិនត្រូវបាន "ចោទប្រកាន់ជាក់លាក់លើបទប្រល័យពូជសាសន៍" ហើយ "ការចោទប្រកាន់នាពេលនេះ អាចជាការចោទប្រកាន់ "បទល្មើស" ផ្សេង"[24]។ ពាក់ព័ន្ធនឹងព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស អង្គបុរេជំនុំជម្រះបានរកឃើញថា ព្រះរាជក្រឹត្យនេះមានការប្រើប្រាស់ពីរខុសគ្នានៃពាក្យ "លើកលែងទោស" ពោលគឺ "ការលើកលែងទោស" និង "លើកលែងទោសពីការចោទប្រកាន់"[25]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា សុពលភាពនៃ "ការលើកលែងទោស" ដែលពាក់ព័ន្ធនឹងបទប្រល័យពូជសាសន៍ មិនមានភាពប្រាកដជាក់លាក់[26] ហើយថា "ការលើកលែងទោសពីការចោទប្រកាន់" ពុំពាក់ព័ន្ធ ដោយសារ បទល្មើសទាំងឡាយដែលមានចែងនៅក្នុងច្បាប់ឆ្នាំ ១៩៩៤ មិនស្ថិតនៅក្រោមយុត្តាធិការរបស់អ.វ.ត.ក ឡើយ[27]។

---

[23] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង សារី ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ ឯកសារលេខ C22/I/74 កថាខណ្ឌ៥២។

[24] *ដូចឯកសារខាងលើ* កថាខណ្ឌ៥១។

[25] *ដូចឯកសារខាងលើ* កថាខណ្ឌ៥៧។

[26] *ដូចឯកសារខាងលើ* កថាខណ្ឌ៥៨។

[27] *ដូចឯកសារខាងលើ* កថាខណ្ឌ៦១។

១៥. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ក.ស.ច.ស បានចេញដីកាដំណោះស្រាយ ដែលក្នុងនោះ ដីកានេះបានគាំទ្រយ៉ាងមានប្រសិទ្ធភាពទៅលើការសន្និដ្ឋានជាបឋមរបស់ខ្លួន ដោយបន្ថែម (ប្រសិនបើមាន) ការវិភាគផ្លូវច្បាប់ថ្មីតិចតួច ដើម្បីបង្ហាញថាហេតុអ្វីបានជា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស និងគោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* មិនអាចយកមកអនុវត្តបាននៅចំពោះមុខអ.វ.ត.ក។ ក.ស.ច.ស បានថ្លែងថា៖

សហចៅក្រមស៊ើបអង្កេតអាចត្រឹមតែអះអាងបន្ថែមទៅលើការវិភាគជាបឋមរបស់ខ្លួនប៉ុណ្ណោះ ។ ដូចនេះ ការលើកលែងទោសគឺមិនមានផលប៉ះពាល់ឡើយ ដោយហេតុថា វិសាលភាពនៃការលើកលែងទោសនេះ គឺបានកម្រិតត្រឹមការចោទប្រកាន់នៅក្នុងក្របខ័ណ្ឌនៃច្បាប់ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤។ ដូចគ្នាដែរ បើទោះជាព្រះរាជក្រឹត្យលើកលែងទោសអាចត្រូវបានយកមកសំអាងនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ក៏វិធានការនេះមិនមានផលប៉ះពាល់លើដំណើរការនីតិវិធីឡើយ ត្បិតវាគ្រាន់តែពាក់ព័ន្ធនឹងមោឃភាពនៃការដាក់ទោស[ស៊ិក] ដែលបានកំណត់ដោយការជំនុំជម្រះក្តីក្នុងឆ្នាំ ១៩៧៩ តែប៉ុណ្ណោះ។... បើទោះជាសន្មតថា ឧក្រិដ្ឋកម្មនានាដែលបានកាត់សេចក្តីនាឆ្នាំ ១៩៧៩ បានបញ្ចូលមួយផ្នែក ឬទាំងស្រុងក្នុងអង្គហេតុបច្ចុប្បន្នដែលបានធ្វើការចោទប្រកាន់ចំពោះ **អៀង សារី** សហចៅក្រមស៊ើបអង្កេតយល់ឃើញថា បញ្ហាដែលចោទឡើងថាតើសាលក្រមនាឆ្នាំ១៩៧៩ នៅតែមានសុពលភាព និងអាចលើកយកមកធ្វើជាសំអាងនៅក្នុងការជំទាស់ទៅនឹងដំណើរការក្តីថ្មីទាក់ទងនឹងបទប្រល័យពូជសាសន៍ចំពោះ អៀង សារី ឬទេនោះ គឺជាយុត្តិកម្មមួយដែលនាំទៅរកការពិភាក្សាដេញដោលជាសាធារណៈ និង ចំពោះមុខ នៅអង្គជំនុំជម្រះសាលាដំបូង ដែលមានតែការពិភាក្សាប្រភេទនេះទេ ដែលអនុញ្ញាតឲ្យជនត្រូវចោទ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី អាចបង្ហាញនូវអំណះអំណាងរបស់ខ្លួនដោយពេញលេញ[28]។

[28] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427 កថាខណ្ឌ១៣៣១, ១៣៣៣។

១៦. នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ មេធាវីការពារក្ដីបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងបញ្ហាយុត្តាធិការដូចបានលើកឡើងក្នុងដីកាដំណោះស្រាយ[29]។ មេធាវីការពារក្ដីបានអះអាងថា ក.ស.ច.ស បានភ័ន្តច្រឡំដោយបញ្ជូនលោក អៀង សារី ទៅជំនុំជម្រះ ព្រោះបញ្ហានៅក្នុងរឿងក្ដីពេលនេះ គឺដូចគ្នានឹងបញ្ហានាឆ្នាំ ១៩៧៩ ដូច្នេះ គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* ដូចមានចែងក្នុងច្បាប់អន្តរជាតិ និងច្បាប់កម្ពុជាជាធរមានគួររារាំងការផ្ដន្ទាទោសបច្ចុប្បន្នចំពោះរូបគាត់។ មេធាវីការពារក្ដីបានអះអាងថា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះ នៅតែមានសុពលភាពផ្នែកច្បាប់នៅកម្ពុជា និងអាចយកមកអនុវត្តបាននៅអ.វ.ត.ក វិសាលភាពនៃព្រះរាជក្រឹត្យលើកលែងទោសការពារលោក អៀង សារី ពីការផ្ដន្ទាទោសនៅអ.វ.ត.ក ហើយព្រះរាជក្រឹត្យអនុគ្រោះទោសធានាលោក អៀង សារី ថា មិនអាចទទួលទោសចំពោះការផ្ដន្ទាទោស ដោយផ្អែកលើអំពើនានា ដែលបានដេញដោលក្នុងការជំនុំជម្រះនាឆ្នាំ ១៩៧៩ ឡើយ។

១៧. នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្ដីបានដាក់សេចក្ដីសង្ខេបនៃអញ្ញត្រកម្មរបស់ខ្លួនចំពោះយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង[30]។ មេធាវីការពារក្ដីត្រូវបានច្រានចោលជាមុនពីការលើកឡើងនូវទឡ្ហីករណ៍ពេញលេញរបស់ខ្លួនលើគោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* និងព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស[31]។ ជំនួសវិញ សេចក្ដីសង្ខេបនេះសំដៅទៅលើសារណាមុនៗរបស់មេធាវីការពារក្ដីអំពីបញ្ហាទាំងនេះ។ នៅពេលដែលដាក់សេចក្ដីសង្ខេបនេះ អង្គបុរេជំនុំជម្រះនៅពុំទាន់បានចេញសាលដីកាពេញលេញលើបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីប្រឆាំងនឹងដីកាដំណោះស្រាយនៅឡើយ។

---

[29] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ឯកសារលេខ D427/1/6។

[30] សេចក្ដីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានានាពេលអនាគត ដែលត្រូវបានចេញជំនួសឲ្យសេចក្ដីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E51/4។

[31] សម្រាប់ការពិភាក្សាលើបញ្ហានេះ *សូមមើល ឯកសារខាងលើ*។

១៨. នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញនូវសាលដីកាពេញលេញរបស់ខ្លួន លើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[32]។ អង្គបុរេជំនុំជម្រះបាន សម្រេចថា គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* ពុំបានរាំងលោក អៀង សារី ពីការចោទប្រកាន់ពេលនេះឡើយ ព្រោះថា **ក**) គោលការណ៍ ដែលមានចែងក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌ(CPC) អាចតែអនុវត្តដើម្បីរាំងការចោទប្រកាន់ថ្មីៗ ក្នុងរឿងក្ដីណា ដែល ការចោទប្រកាន់មុន ទទួលលទ្ធផលសម្រេចឲ្យរួចពីបទចោទប៉ុណ្ណោះ[33] **ខ**)គោលការណ៍ ដូច មានចែងក្នុង ICCPR មានអានុភាពក្នុងស្រុកទាំងស្រុង និងមិនអាចអនុវត្តនៅអ.វ.ត.ក បានឡើយ ដែលតុលាការនេះត្រូវបានគេមើលឃើញថាជា តុលាការ "ដែលមានលក្ខណៈជាអន្តរជាតិ"[34] និង**គ**) វិធាននីតិវិធី ដែលត្រូវបានបង្កើតនៅកម្រិតអន្តរជាតិមានការលើកលែងចំពោះគោលការណ៍ ដែលការជំនុំជម្រះមុនពុំមានឯករាជ្យភាព ឬភាពមិនលម្អៀង ហើយការជំនុំជម្រះពីមុនចំពោះ លោក អៀង សារី ស្ថិតក្នុងករណីលើកលែងនេះ[35]។ អង្គបុរេជំនុំជម្រះបានសម្រេចថា ព្រះរាជ ក្រឹត្យលើកលែងទោស និងអនុគ្រោះទោស មិនរាំងលោក អៀង សារី ពីការចោទប្រកាន់នាពេល នេះឡើយ ព្រោះថា **ក**) ព្រះរាជក្រឹត្យលើកលែងទោស ត្រូវបានភ្ជាប់ជាមួយនឹងការកាត់ទោស ដោយគ្មានសុពលភាពនៅក្នុងឆ្នាំ ១៩៧៩ ការលើកលែងទោសនេះមិនមានអានុភាពលើយុត្តាធិការ របស់អវតក ដើម្បីជំនុំជម្រះក្ដីលើ អៀង សារី ពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងដីកា ដំណោះស្រាយនោះទេ[36] **ខ**) ព្រះរាជក្រឹត្យអនុគ្រោះទោសអាចរាំងមិនឲ្យមានការជំនុំជម្រះលោក អៀង សារី តែទៅលើបទល្មើសប្រឆាំងសន្តិសុខរដ្ឋ ដូចមានចែងក្នុងមាត្រា៤នៃច្បាប់ឆ្នាំ ១៩៩៤ ហើយប្រហែលជាអាចរាំងទៅលើបទល្មើស នៃសមាជិកភាពក្នុងក្រុមកម្ពុជាប្រជាធិបតេយ្យ[37]

---

[32] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D427/1/30។

[33] *ដូចឯកសារខាងលើ* កថាខណ្ឌ១១៩-២៤។

[34] *ដូចឯកសារខាងលើ* កថាខណ្ឌ១២៧-៣១។

[35] *ដូចឯកសារខាងលើ* កថាខណ្ឌ១៣២-៣៥។

[36] *ដូចឯកសារខាងលើ* កថាខណ្ឌ១៩៥។

[37] *ដូចឯកសារខាងលើ* កថាខណ្ឌ២០០។

គ) ការផ្តល់នូវការលើកលែងទោស ដោយមិនបានធ្វើការជំនុំជម្រះ និងផ្តន្ទាទោសនោះ នឹងនាំដល់ការមិនគោរពតាមកាតព្វកិច្ចរបស់ប្រទេសកម្ពុជាចំពោះសន្ធិសញ្ញា ក្នុងការជំនុំជម្រះ និងផ្តន្ទាទោសចំពោះអ្នករៀបចំបង្កើតបទល្មើសទាំងនោះ ដូចមានចែងក្នុងអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងអនុសញ្ញាទីក្រុងហ្សឺណែវ[38] និង ឃ) ការផ្តល់នូវការលើកលែងទោស នឹងមិនគោរពតាមកាតព្វកិច្ចរបស់ប្រទេសកម្ពុជាចំពោះ ICCPR ដែលត្រូវជំនុំជម្រះ និងផ្តន្ទាទោស ចំពោះអ្នករៀបចំបង្កើតអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ឬក៏ការផ្តល់នូវការជួសជុលប្រកបដោយប្រសិទ្ធភាពចំពោះជនរងគ្រោះផងដែរ[39]។

១៩. នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ មេធាវីការងារក្តីបានដាក់សេចក្តីថ្លែងការណ៍របស់លោក អៀង សារី ដែលនៅក្នុងនោះ គាត់បានពន្យល់អំពីវិសាលភាព ចេតនានៅពីក្រោយ និងសារតានៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស[40]។ នៅថ្ងៃដដែលនេះ មេធាវីការពារក្តីបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងសុំឃាង និងកោះអញ្ជើញសម្តេចព្រះវររាជបិតា នរោត្តម សីហនុ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងសម្តេច ជា ស៊ីមឲ្យផ្តល់ភស្តុតាង ទៅតាមវិសាលភាពដែលជាចេតនានៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស[41]។

២០. នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ មេធាវីការពារក្តីបានដាក់ សារណាបន្ថែមលើអញ្ញត្រកម្មរបស់ខ្លួន ដោយផ្អែកលើព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស និងសារណាបន្ថែមលើអញ្ញត្រកម្មរបស់ខ្លួន ដោយផ្អែកលើ (គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែ*

---

[38] *ដូចឯកសារខាងលើ* កថាខណ្ឌ ២០១។

[39] *ដូចឯកសារខាងលើ* ។

[40] សេចក្តីថ្លែងការណ៍របស់លោក អៀង សារី ទាក់ទងនឹងវិសាលភាព ចេតនានៅពីក្រោយ និងសារតានៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារលេខ E84។

[41] ញត្តិរបស់លោក អៀង សារី សុំឃាង និងកោះអញ្ជើញសម្តេចព្រះវររាជបិតា នរោត្តម សីហនុ សម្រេច នាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងសម្តេច ជា ស៊ីម ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១ ឯកសារលេខ E85។

បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្រកម្ម អនុលោមតាមវិធាន៨៩ (គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោស) របស់ អៀង សារី

*មួយ*[42]។ សារណាបន្ថែមទាំងនេះបានពន្យល់អំពីកំហុសឆ្គងក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ និងបានឆ្លើយតបនឹងសំណួរជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូង[43]។

២១. នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ មេធាវីការពារក្ដី ក.ស.ព និងភាគីដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញទឡ្ហីករណ៍ផ្ទាល់មាត់លើបញ្ហានានាពាក់ព័ន្ធនឹងព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស និងគោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* នៅសវនាការបឋម[44]។

២២. នៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចដែលត្រូវបានជំទាស់។

[42] សារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្ម អនុលោមតាមវិធាន៨៩ (គោលការណ៍ *គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ* ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ E51/11។ សារណាបន្ថែមរបស់ លោក អៀង សារី លើអញ្ញត្រកម្មរបស់គាត់ ដែលធ្វើតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*ការលើកលែងទោស និងការអនុគ្រោះទោស*) ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ E51/10។

[43] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖ ការដាក់អញ្ញត្រកម្មបន្ថែម (*ការលើកលែងទោស និងការអនុគ្រោះទោស*) ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ E51/8។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖ ការដាក់អញ្ញត្រកម្មបន្ថែម (គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*) ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ E51/9។

[44] ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E1/4.1។ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E1/5.1។